**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ពន្ធដារ

**អគ្គនាយកដ្ឋានពន្ធដារ**

**នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ........១៣៧........អពដ

# សេចក្តីជូនដំណឹង

អនុលោមតាមមាត្រា៧១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ក្នុងករណីដែលមូលនិធិពាណិជ្ជកម្ម ឬសហគ្រាស ឬអសង្ហារឹម ត្រូវបានលក់ អ្នកទិញនិងអ្នកលក់ត្រូវទទួលខុសត្រូវរួមគ្នាក្នុងការសងប្រាក់ពន្ធនិងប្រាក់ពិន័យ ដែលត្រូវបង់ដោយអ្នកលក់នាពេលលក់ ។

អាស្រ័យហេតុនេះ អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនដំណឹងដល់ អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី ជាអភិបាលឬបណ្ណាធិការសហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដូចខាងក្រោម ៖

១- ក្នុងករណីដែលមានការទិញ-លក់ សហគ្រាស ដែលក្នុងនោះរួមទាំងការទិញ-លក់ ភាគហ៊ុនទាំងស្រុង ឬចំណែកណាមួយនៃភាគហ៊ុនរបស់សហគ្រាស ភាគីលក់ត្រូវតែធ្វើការជម្រះបំណុលពន្ធឲ្យបានស្រេចបាច់មុននឹងធ្វើការលក់ ។ ការជម្រះបំណុលពន្ធត្រូវធ្វើឡើងតាមរយៈការទូទាត់រាល់បំណុលពន្ធដែលកើតមានឡើងក្រោយការធ្វើសវនកម្មពន្ធដារ ។

២- ភាគីទិញត្រូវទទួលខុសត្រូវទាំងស្រុង ចំពោះបំណុលពន្ធនានា ដែលកើតមានឡើង ទោះបីក្នុងអំឡុងពេលដែលភាគីលក់បានកាន់កាប់ ឬក្នុងអំឡុងពេលដែលសាមីភាគីទិញកាន់កាប់ក៏ដោយ ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមជឿជាក់ថា អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី ពិតជាអនុវត្តបានត្រឹមត្រូវតាមខ្លឹមសារនៃលិខិតជូនដំណឹងនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០១២

អគ្គនាយកដ្ឋានពន្ធដារ

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៨៨៦ ៧០៨ / ទូរសារ: (៨៥៥) ២៣ ៨៨៦ ៧០០
CORNER RUSSIAN FEDERATION & MAO TSETONG BLVD. TOEK LAAK 1, TOUL KAUK, PHNOM PHNOM PENH Phone: (855) 23 886 708 / Fax: (855) 23 886 700